ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមករា ឆ្នាំ២០២៣

នៅក្នុងខែមករា ឆ្នាំ២០២៣នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា

១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០១លើក។

១.១.២-បដិសណ្ឋារកិច្ចឡើជាតិ-អន្តរជាតិ

-បានអនុញ្ញាតជូនឯកអគ្គរាជទូតតែងតាំងថ្មី នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសជាមិត្តចំនួន០៨រូប ចូលជួបសម្តែងការគួរសម និងជម្រាបលា នៅវិមានព្រឹទ្ធសភា។

១.១.៣-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៩ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៨ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣។

១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០១លើក។

១.២.២-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានទទួលជ្រាបជាព័ត៌មានចំនួន៥០ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០១លើក។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

**១.៣.២-សកម្មភាពចុះមូលដ្ឋាន**

-បានអនុញ្ញាតឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋចំនួន៥១៨នាក់ ស្ថិតនៅសង្កាត់ដើមមៀន ក្រុងតាខ្មៅ ឃុំព្រែកទន្លាប់ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល។

**១.៣.៣-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញទស្សនាការហាត់សមរបាំ ដើម្បីត្រៀមសម្តែងក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ៧មករា នៅនាយកដ្ឋានសិល្បៈទស្សនីយភាព នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រាជធានីភ្នំពេញ

-បានអញ្ជើញក្រុងពាលីសុំសេចក្តីសុខ និងចូលរួមជាគណៈអធិបតីក្នុងពិធីខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ៧មករា នៅទីក្រុងកោះពេជ្រ រាជធានីភ្នំពេញ។

**១.៣.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៣ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ និងសម្រេចលើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២២

២-ពិនិត្យ និងសម្រេចលើគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២៣។

## ៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៣.១ មុខងារនីតិកម្ម

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យ និងឆ្លងឯកសារស្តីពី លទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦។

**៣.២ មុខងារតាមដានការអនុវត្តច្បាប់**

-បានអញ្ជើញជួបប្រជុំការងារជាមួយ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងសហការី ដើម្បីឈ្វេងយល់ពីការវិវឌ្ឍការងារ បញ្ហាប្រឈម និងចក្ខុវិស័យរបស់រាជបណ្ឌិត្យសភាកម្ពុជា នៅសាលប្រជុំរាជបណ្ឌិត្យសភាកម្ពុជា។

**៣.៣ មុខងារតំណាង**

-បានទទួលពាក្យបណ្ដឹងចំនួន០៧ករណី បញ្ជូនទៅក្រសួង-ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី កំពុងពិនិត្យសិក្សាចំនួន១១ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្ដឹងពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងបានចំនួន០៥ករណី និងបានទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី

-បានអញ្ជើញចូលរួមប្រជុំពិភាក្សាអំពីការរៀបចំគ្រឿងឥស្សរិយយស បំពាក់ជូនសមាជិកព្រឹទ្ធសភាចុងនីតិកាលទី៤ នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ស្ដីពីសកម្មភាព និងលទ្ធផលការងារឆ្នាំ២០២២ និងទិសដៅបន្តឆ្នាំ២០២៣

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២, ទី៧, ទី៨ បានប្រជុំពិនិត្យពិភាក្សាលើ៖ ១.ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣ ២.របាយការណ៍ស្ដីពីលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារបន្តឆ្នាំ២០២៣ ៣.របាយការណ៍ថវិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ និង៤.បញ្ហាផ្សេងៗ

-បានអញ្ជើញជួបប្រជុំជាមួយក្រុមការងាររបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិវណ្ណសិប្បសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមប្រជុំ ដើម្បីត្រៀមរៀបចំវេទិការវាងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ជាមួយក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌទាំង១៤ ចំណុះរាជធានីភ្នំពេញ និងបញ្ហាផ្សេងៗ

-បានអញ្ជើញចូលរួមប្រជុំពិនិត្យ និងពិភាក្សាជាមួយគណៈកម្មការសាងសង់សាលាមួយខ្នងមានប្រាំបន្ទប់ នៃសាលាបឋមសិក្សាពោធិ៍ព្រឹក្ស នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

-បានអញ្ជើញចូលរួមកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីក្របខណ្ឌគណនេយ្យ-ភាពជាពហុវិស័យ សម្រាប់ឆ្លើយតបនឹងជំងឺរបេង ក្នុងចំណោមអន្តរក្រសួង ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំស្តាប់បទបង្ហាញរបស់តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លើករណីលិខិតអន្តរាគមន៍របស់ ឯកឧត្តម **អ៊ុង ទី** ប្រធានសហគមន៍គ្រីស្តបរិស័ទគណៈនិកាយប្រូតេស្តង់កម្ពុជា នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះពិនិត្យ និងព្យាបាលជំងឺភ្នែកជូនប្រជាពលរដ្ឋចំនួន៩០០នាក់ នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ

-បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចឧត្តមទេពញាណ **ហ៊ុន ណេង** ចំនួន៥៥នាក់ ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋចំនួន៣៩៣នាក់ នៅឃុំទួល-ព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

-បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌ប្រចាំនៅកម្ពុជារបស់ប្រទេសបារាំង (AMH) មកព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅស្រុកកំរៀង ខេត្តបាត់ដំបង

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាជ័យជម្នះ ៧មករា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលពិព័ណ៌កោះពេជ្រ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីជួបសំណេះសំណាល និងពិសារអាហារសាមគ្គី ជាមួយបងប្អូនអ្នកសារព័ត៌មានលើកទី៥ ប្រមាណជិត៥,០០០នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលពិព័ណ៌កោះពេជ្រ

-បានអញ្ជើញទៅចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី៦ នៅសាលសិក្ខាសាលាខាងត្បូងវិមានព្រឹទ្ធសភា

-បានអញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធសមិទ្ធផល និងចូលរួមជាកិត្តិយស ក្នុងពិធីផ្លូវការផ្សេងៗចំនួន៦៤លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេសបានចែកថ្នាំពេទ្យ បរិក្ខារពេទ្យ និងឧបករណ៍តេស្តរហ័សជូនមណ្ឌលសុខភាពនៅតាមបណ្តាខេត្ត ក្រុងនានា ចំនួន១២៥លើក។

### ៣.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាតលើកទី១៣ របស់សភាតំបន់អាស៊ី(APA) នៅទីក្រុងអានតាលីយ៉ា ប្រទេសតួកគី

-បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមមិត្តភាព នៃសភាទាំងពីរ (កម្ពុជា-វៀតណាម) នៅទីក្រុង Da Nang និងខេត្ត Quang Nam នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានអនុញ្ញាតឱ្យឯកឧត្តម Damien Regnard សមាជិកព្រឹទ្ធសភាបារាំងតំណាងឱ្យប្រជាពលរដ្ឋបារាំងនៅបរទេស និងជាសមាជិកគណៈកម្មការវប្បធម៌ អប់រំ និងទំនាក់ទំនងនៃព្រឹទ្ធសភាបារាំង ចូលជួបពិភាក្សាការងារ ក្នុងឱកាសឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាន់ខ្ពស់ នៃប្រទេសទាំងពីរកម្ពុជា-បារាំង ដើម្បីផ្លាស់ប្តូរព័ត៌មាន និងលើកកម្ពស់ភាសាបារាំង នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យលោកស្រី Jimin Jeong ប្រធានគ្រប់គ្រង G Foundation នៃអង្គការចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ និងសហការី ចូលជួបពិភាក្សា

ការងារស្តីពីការគ្រប់គ្រង និងប្រើប្រាស់អំណោយមនុស្សធម៌របស់អង្គការចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ និងគម្រោងកិច្ចសហប្រតិបត្តិការបន្ត នៅវិមានព្រឹទ្ធសភា។

-បានអញ្ជើញទទួលជួបភ្ញៀវជនជាតិចិនចំនួន១៣នាក់ អញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់ និងទស្សនាភោជនីយដ្ឋានចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ។

ថ្ងៃអង្គារ ១០កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២៣

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

**កិត្តិសង្គហបណ្ឌិត ទេព ងន**

*ចម្លងជូន*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*

*(ជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*